ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការចិញ្ចឹមត្រីឆ្តោរក្នុងស្រះ







គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃធនាគារ អេ.អ.ឌី.ប៊ី

ឆ្នាំ ២០២២

## **១-លក្ខណៈជីវសាស្ត្ររបស់ត្រីឆ្តោរ**

ត្រីឆ្តោរ ជាត្រីទឹកសាប ប្រភេទមំសាសី ពោលគឺស៊ីសាច់ជាអាហារ។ ក្នុងវ័យជំទង់គេហៅថា ត្រីដៀប ពេលធំពេញវ័យហៅត្រីឆ្តោរ មានឈ្មោះវិទ្យាសាស្ត្រ (Channa maculatus) និងឈ្មោះជាភាសាអង់គ្លេស Giant Snakehead។ ត្រីប្រភេទនេះមានរស់នៅពាសពេញតំបន់អាស៊ីអាគ្នេយ៍ ចាប់ពីទន្លេមេគង្គភាគខាងក្រោមក្នុងប្រទេសឡាវ នៅអាងទន្លេចៅប្រាយ៉ា និងទន្លេមេក្លង ក្នុងប្រទេសថៃ នៅបឹងទន្លេសាប ក្នុងប្រទេសកម្ពុជា និងនៅតំបន់ដីសណ្តទន្លេមេគង្គ ក្នុងប្រទេសវៀតណាម។ ត្រីដៀប/ឆ្តោរ មានប្រវែងដងខ្លួនអតិបរមា ១៣០ស.ម និងទម្ងន់ ២០គីឡូក្រាម។ ការសម្របខ្លួនរបស់វាទៅនឹងបរិយាកាសជុំវិញគឺខ្លាំង ទោះបីជានៅក្នុងទឹកដែលមានបរិមាណអុកស៊ីសែនទាប ដោយសារសរីរាង្គផ្លូវដង្ហើមរបស់វាអាចដកដង្ហើមនៅក្នុងខ្យល់បាន។ កម្រិតសីតុណ្ហភាពទឹកសមស្របបំផុតចន្លោះពី ២៨-៣២°c និងកម្រិត pH ៦,៥-៨,៥។

ត្រីឆ្តោរ ជាប្រភេទត្រីកាច ស៊ីចំណីចម្រុះ ចំណីចម្បងគឺស៊ីត្រីផ្សេងៗ ប៉ុន្តែវាក៏ស៊ីពពួកចៃទឹក ឬសត្វល្អិតដែលរស់ក្នុងទឹកផងដែរ និងសម្រាប់ការចិញ្ចឹមក្នុងស្រះឬអាង វាក៏អាចស៊ីចំណីកែឆ្នៃ។ រយៈពេលចិញ្ចឹមពី ៨ ទៅ ១០ខែ អាចទទួលបានទម្ងន់ចន្លោះពី ១,២ ទៅ ២,៥គ.ក/ក្បាល (ចំណី និងថែទាំបានល្អ)។ ត្រីឆ្តោរញីមានអាយុ ១ឆ្នាំ អាចបង្កកំណើតបានចាប់ពីខែមេសាដល់ខែកក្កដា នៅតាមទន្លេរាក់ៗ វាលទំនាប តាមស្ទឹង ប្រឡាយ បឹងធំៗ ដែលមានទឹកនឹង ឬហូរយឺតៗ។

## **២-វិធីសាស្ត្រចិញ្ចឹម÷**

វិធីសាស្ត្រនៃការចិញ្ចឹមត្រីឆ្តោរ គឺអាស្រ័យទៅលើស្ថានភាពនៃការចិញ្ចឹមខុសៗគ្នាមានដូចជា ការចិញ្ចឹមក្នុងស្រះ ចិញ្ចឹមក្នុងបែរ ក្នុងអាងស៊ីម៉ង់ត៍ និងក្នុងអាងចង់ប្លាស្ទិចជាដើម។ កសិករអាចចិញ្ចឹមបានពេញមួយឆ្នាំ ប្រសិនបើកសិករអាចរកចំណីផ្គត់ផ្គង់បាន។ តាមការសិក្សាអំពីបទពិសោធន៍នៅតាមកសិដ្ឋានចិញ្ចឹមត្រីឆ្តោរបានបង្ហាញថា ការចិញ្ចឹមត្រីឆ្តោរមានរដូវកាលឬដំណាក់កាលនៃការដាក់ចិញ្ចឹមដើម្បីតម្រូវប្រភពចំណី និងមានទីផ្សារល្អ។

- **ដំណាក់កាលទី១÷** ចាប់ផ្តើមចិញ្ចឹមនៅខែ សីហា-កញ្ញា អាចប្រមូលបាននៅខែ មិថុនា និងកក្កដា។ នៅដំណាក់កាលនេះ ត្រីក៏អាចធំធាត់បានលឿន ព្រោះសម្បូរចំណីជាត្រីល្អិត។
- **ដំណាក់កាលទី២÷** កសិករអាចដាក់ចិញ្ចឹមនៅខែមករា ប៉ុន្តែមិនសូវចំណេញដោយសារខ្សត់ចំណីនិងមានតម្លៃថ្លៃ

ខាងក្រោមនេះជាមូលដ្ឋានគ្រឹះបច្ចេកទេសនៃការចិញ្ចឹមត្រីឆ្តោរ ក្នុងស្រះ ដែលមានលក្ខណៈសាមញ្ញ និងងាយស្រួលសម្រាប់កសិករយកទៅអនុវត្ត និងរៀនសូត្របន្ថែម។

**២.១. ការរៀបចំស្រះ÷** ស្រះចិញ្ចឹមត្រីថ្មីគួររៀបចំឡើងលើទីតាំងសមស្របដូចខាងក្រោម÷

- មានប្រភពទឹកស្អាតនៅជិត
- ដីជ្រាបទឹកតិច ឬមិនជ្រាបទឹក
- មិនលិចទឹកនៅរដូវវស្សា
- ទទួលពន្លឺថ្ងៃគ្រប់គ្រាន់

**ការរៀបចំស្រះត្រីមុនពេលដាក់ត្រីចិញ្ចឹម÷**

- សម្អាតសំរាម និងកាកសំណល់ផ្សេងៗនៅក្នុងស្រះ
- ហាលស្រះឱ្យស្ងួត ដើម្បីកម្ចាត់ពពួកសត្វកាច និងបន្សាបជាតិពុលនៅបាតស្រះ

- បាចកំបោរ កម្ចាត់ពពួកសត្វកាច និងបង្កើនគុណភាពទឹកជាមួយបរិមាណកំបោរ ១០-១៥ គ.ក/១០០ម$^{២}$ និងទុករយៈពេលពី ២-៥ថ្ងៃ។
- ហ៊ុំស្បៃព័ទ្ធជុំវិញស្រះ ដើម្បីការពារត្រីខាងក្រៅចូលក្នុងស្រះ ការពារកូនត្រីខាងក្នុងចេញ និងការពារសត្វផ្សេងចូលក្នុងស្រះដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក។
- បញ្ចូលទឹកក្នុងស្រះ ជម្រៅទឹកពី ១,៥ ទៅ ២ម៉ែត្រ ក្រោយបាចកំបោរបាន ៣-៥ថ្ងៃ

### ២.២. ការដាក់កូនត្រី និងការលែងកូនត្រី÷

កូនត្រីពូជដាក់ចិញ្ចឹមត្រូវមានទំហំស្មើគ្នា មិនមានរបួសស្នាម រហ័សរហួន សុខភាពល្អ ពណ៌ស្រស់ថ្លា និងទំហំកូនត្រីពូជចន្លោះពី ១៥-២០ក្រាម/ក្បាល។ មុនព្រលែងកូនត្រីចូលទៅក្នុងស្រះចិញ្ចឹម កូនត្រីពូជគួរលាងសម្អាតដោយការត្រាំទឹកអំបិលជាមុនសិន ជាមួយកំហាប់អំបិល ៣% រយៈពេល ៥-១០នាទី ដើម្បីសម្លាប់មេរោគ និងពពួកប៉ារ៉ាស៊ីត។ គួរព្រលែងកូនត្រីនៅពេលព្រឹកព្រលឹមឬពេលល្ងាចដែលមានមេឃត្រជាក់គឺល្អបំផុត ជាមួយដង់ស៊ីតេចន្លោះពី ៨-១០កូន/ម៉ែត្រការ៉េ ឬអាចចន្លោះពី ២៥-៣០កូន/ម៉ែត្រការ៉េ អាស្រ័យលើលក្ខខណ្ឌនៃការគ្រប់គ្រងគុណភាពទឹក និងចំណីបានគ្រប់គ្រាន់។

### ២.៣. ចំណី និងការផ្តល់ចំណី÷

ត្រីឆ្តោរ ជាប្រភេទត្រីកាច ស៊ីចំណីចម្រុះ ប៉ុន្តែចំណីចម្បង គឺស៊ីត្រីផ្សេងៗ ដូចជា ត្រីល្អិតសមុទ្រ ត្រីទឹកសាប កូនកង្កែប ខ្យង និងប្រភេទកាកសំណល់ផ្សេងៗ។ ចំណីត្រូវកិនឬចិញ្ច្រាំ ឱ្យល្អិតសមល្មមទៅតាមទំហំដងខ្លួនរបស់កូនត្រី។ ជាពិសេសគឺអំឡុងពេលកូនត្រីនៅអាយុ ២ខែដំបូង ចំណីត្រូវកិនឱ្យបានម៉ត់ល្អ។ បរិមាណចំណីគឺ ៣-៥% នៃទម្ងន់ត្រី/ថ្ងៃ ដោយតួលេខនេះនឹងចាប់ផ្តើមថយចុះម្តងបន្តិចៗនៅពេលត្រីកាន់តែធំ។ សមាមាត្រចំណីធៀបនឹងទម្ងន់ត្រី (FCR) គឺអាស្រ័យលើប្រភេទចំណីឬកម្រិតប្រូតេអ៊ីនរបស់ចំណីដែលបានផ្តល់។ ជាទូទៅ ប្រសិនបើការចិញ្ចឹមដោយផ្តល់ចំណីជាប្រភេទកូនត្រីល្អិត (ត្រីនុយ) កម្រិត FCR ប្រមាណជា ៣,៥-៤ គីឡូក្រាមចំណី/គីឡូក្រាមត្រី។

### ២.៤. ការថែទាំ÷

ត្រូវតាមដានសកម្មភាពត្រីក្នុងស្រះឱ្យបានទៀងទាត់ ដើម្បីរកឱ្យឃើញនូវសញ្ញាចម្លែកៗដូចជា ត្រីមិនស៊ីចំណី ហែលទឹកខុសប្រក្រតី មានមេរោគជាដើម ដើម្បីមានវិធានការណ៍ព្យាបាលទាន់ពេលវេលា។ ការតាមដានលើចរិកស៊ីចំណី និងបរិមាណចំណីជាប្រចាំ ដើម្បីអាចគ្រប់គ្រងឬកែតម្រូវបរិមាណចំណីដែលត្រូវផ្តល់នៅថ្ងៃបន្ទាប់។ ទឹកនៅក្នុងស្រះត្រូវផ្លាស់ប្តូរជាប្រចាំ ២-៣ដង/ខែ អាស្រ័យលើគុណភាពទឹកក្នុងស្រះ ដោយត្រូវរក្សាកម្រិត pH ចន្លោះពី ៦,៥-៨,៥ និងកម្រិតថ្លានៃទឹកចន្លោះពី ៣៥-៤០សង់ទីម៉ែត្រ។ បរិមាណទឹកដែលត្រូវផ្លាស់ប្តូរចន្លោះពី ៣០-៤០%។

### ២.៥. ការប្រមូលផល÷

រយៈពេលនៃការចិញ្ចឹមត្រីឆ្តោរពី ៨-១០ខែ អាចទទួលបានត្រីទម្ងន់ចន្លោះពី ១,២ ទៅ ២,៥ គ.ក/ក្បាល។ កសិករអាចប្រមូលផលបានតាមភាពជាក់ស្តែង ដោយអាស្រ័យលើការធំធាត់/ទំហំត្រី និងតម្លៃទីផ្សារ ។ មុនពេលប្រមូលផល ១-២ថ្ងៃគួរកាត់បន្ថយបរិមាណចំណី ឬផ្តាច់ចំណីនៅថ្ងៃប្រមូលផល។

### ៣-គម្រោងនៃការចំណាយសម្រាប់ការចិញ្ចឹមត្រីឆ្ពោរក្នុងស្រះ

- ទំហំស្រះ ÷ បណ្ដោយ ៣៥ម៉ែត្រ ទទឹង ២៥ម៉ែត្រ និងជម្រៅ ៥ម៉ែត្រ (ជម្រៅទឹកចន្លោះពី ១.៥-២ម៉)
- ចំនួនកូនត្រីពូជ ÷ **១០,០០០ ក្បាល**
- រយៈពេលចិញ្ចឹម ÷ ៨-១០ខែ
- ចំណាយទុន ÷ **១៤៥,០៤០,០០០ រៀល**

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| **ចំណាយសរុប ក+ខ** | | | | | **145,040,000** |
| **ក-ការចំណាយប្រែប្រួល** | | | | | **127,960,000** |
| 1 | កំបោរស (រៀបចំស្រះ) | គ.ក | 90 | 2,000 | 180,000 |
| 2 | កូនត្រី (ទំហំ ៤លី) | ក្បាល | 10,000 | 150 | 1,500,000 |
| 3 | ចំណី (ត្រីនុយទឹកសាបពីវៀតណាម) | គ.ក | 54,200 | 2,000 | 108,400,000 |
| 4 | ប្រេងបូមទឹក/វគ្គចិញ្ចឹម | លីត្រ | 1200 | 4,900 | 5,880,000 |
| 5 | កម្លាំងពលកម្ម/វគ្គចិញ្ចឹម | ខែ | 10 | 900,000 | 9,000,000 |
| 6 | ថ្នាំការពារ និងព្យាបាលជម្ងឺ | ខែ | 10 | 300,000 | 3,000,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **17,080,000** |
| 1 | ជីកស្រះ (៣៥ម x២៥ម x ៥ម) | ស្រះ | 1 | 9,200,000 | 9,200,000 |
| 2 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 2,800,000 | 2,800,000 |
| 3 | ម៉ាស៊ីនកិនចំណី | គ្រឿង | 1 | 1,300,000 | 1,300,000 |
| 4 | បំពង់បូមទឹក (ប្រព័ន្ធទឹកកប់ក្នុងដី ៥០០ម) | ដើម | 126 | 30000 | 3,780,000 |

#### ៣-១-ការវិភាគសេដ្ឋកិច្ច

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | ចំនួនវដ្ដ វិលោះ | តម្លៃសរុប/វដ្ត(រៀល) |
|---|---|---|---|---|---|---|
| **ចំណូលពីការលក់ត្រី** (អត្រាបាត់បង់២០% កូនត្រីនៅសល់ ៨,០០០ក្បាល និងទម្ងន់ត្រីមធ្យម ១.៨គ.ក/ក្បាល) | | | | | | |
| 1 | ចំណូលពីការលក់ត្រី | គ.ក | 14,400 | 10,400 | | **149,760,000** |
| **ចំណាយសរុប (ក + ខ)** | | | | | | **129,618,000** |
| **ក-ការចំណាយប្រែប្រួល** | | | | | | **127,960,000** |
| 1 | កំបោរស (រៀបចំស្រះ) | គ.ក | 90 | 2,000 | | 180,000 |
| 2 | កូនត្រី | ក្បាល | 10,000 | 150 | | 1,500,000 |
| 3 | ចំណី (ត្រីនុយ) | គ.ក | 54,200 | 2,000 | | 108,400,000 |

| | | | | | | |
|---|---|---|---|---|---|---|
| 4 | ប្រេងបូមទឹក/វគ្គចិញ្ចឹម | លីត្រ | 1200 | 4,900 | | 5,880,000 |
| 5 | កម្លាំងពលកម្ម/វគ្គចិញ្ចឹម | ខែ | 10 | 900,000 | | 9,000,000 |
| 6 | ថ្នាំការពារ និងព្យាបាលជម្ងឺ | ខែ | 10 | 300,000 | | 3,000,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **1,658,000** |
| 1 | ជីកស្រះ (៣៥ម x ២៥ម x ៥ម) | ស្រះ | 1 | 9,200,000 | 20 | 460,000 |
| 2 | ម៉ាស៊ីនបូមទឹក និងប្រព័ន្ធបែងចែកតាមស្រះ | គ្រឿង | 1 | 2,800,000 | 5 | 560,000 |
| 3 | ម៉ាស៊ីនកិនចំណី | គ្រឿង | 1 | 1,300,000 | 5 | 260,000 |
| 4 | បំពង់បូមទឹក(ប្រព័ន្ធទឹក) | ដើម | 126 | 30,000 | 10 | 378,000 |
| ចំណាយថ្លៃដើមក្នុងការចិញ្ចឹមត្រីក្នុង១ គ.ក | | | | | | **9,001** |
| ចំណេញពីការផលិតត្រីសាច់ ១ គ.ក | | | | | | **1,399** |

**៣-២-ការវិភាគលើតម្លៃលក់**

| **ទិន្នផល (គ.ក)** | **តម្លៃត្រីលក់ចេញ (រៀល)** | **ចំណូលសរុប (រៀល)** | **ចំណាយសរុប (រៀល)** | **ចំណេញ (រៀល)** | **កំណត់សម្គាល់អំពីទិន្នផល** |
|---|---|---|---|---|---|
| 10,800 | 9,000 | 97,200,000 | 97,218,000 | -18000 | ករណីត្រីជួបជម្ងឺការគ្រប់គ្រងមិនទាន់ពេលវេលា អត្រាបាត់បង់ ៤០% |
| | 9,500 | 102,600,000 | 97,218,000 | 5,382,000 | |
| | 10,000 | 108,000,000 | 97,218,000 | 10,782,000 | |
| | 10,400 | 112,320,000 | 97,218,000 | 15,102,000 | |
| | 11,000 | 118,800,000 | 97,218,000 | 21,582,000 | |
| 14,400 | 9,000 | 129,600,000 | 129,618,000 | -18000 | ករណីត្រីជួបជម្ងឺ ការគ្រប់គ្រងទាន់ពេលវេលា អត្រាបាត់បង់ ២០% |
| | 9,500 | 136,800,000 | 129,618,000 | 7,182,000 | |
| | 10,000 | 144,000,000 | 129,618,000 | 14,382,000 | |
| | 10,400 | 149,760,000 | 129,618,000 | 20,142,000 | |
| | 11,000 | 158,400,000 | 129,618,000 | 28,782,000 | |

***កំណត់សម្គាល់÷***

- ក្នុងករណីអត្រាបាត់បង់តិច ចំនួនកូនត្រីនៅសល់ច្រើន នាំឱ្យការចំណាយលើចំណីច្រើន
- ក្នុងករណី ត្រីកើតជម្ងឺ និងងាប់ច្រើននៅពេលត្រីមានអាយុច្រើន នាំឱ្យការចំណាយលើចំណីខ្ពស់ និងការខាតបង់កាន់តែខ្ពស់។

## ៤-ហានិភ័យ៖

តាមរយៈនៃការចុះសិក្សាជាមួយកសិករចិញ្ចឹមត្រីឆ្ពោរ នៅឃុំលើកដែក ស្រុកកោះធំ និងឃុំគគីធំ ស្រុកកៀនស្វាយ មានហានិភ័យមួយចំនួនដែលអាចកើតឡើងជាយថាហេតុលើដំណើរការចិញ្ចឹម នាំឱ្យបង្កផលវិបាក និងផលប៉ះពាល់ដល់សមត្ថភាពផលិតកម្មចិញ្ចឹមត្រីឆ្ពោររបស់កសិករ។ កសិករគួររៀបចំផែនការជាក់លាក់ ដើម្បីកាត់បន្ថយឬគ្រប់គ្រងហានិភ័យបានប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ហានិភ័យចម្បងៗរួមមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ហានិភ័យ | វិធានការ |
| --- | --- | --- | --- |
| ១ | **ហានិភ័យផលិតកម្ម** | ត្រីមានជម្ងឺ និងងាប់ច្រើន នាំឱ្យអត្រាបាត់បង់ខ្ពស់។ | **កសិករចិញ្ចឹមគួរតែ÷**<br>- មានសម្ភារៈសម្រាប់ពិនិត្យគុណភាពទឹកនៅក្នុងកសិដ្ឋាន(សម្ភារៈពិនិត្យ pH, កម្រិតថ្លានៃទឹក កម្រិតជាតិពុលនៃទឹក) និងពិនិត្យជាប្រចាំ ដើម្បីបង្ការ និងការពារករណីត្រីពុលទឹក និងជម្ងឺត្រីកើតឡើង។<br>- តាមដានជាប្រចាំអំពីស្ថានភាពឬសកម្មភាពរបស់ត្រី នៅពេលព្រឹកព្រលឹម និងពេលស៊ីចំណី ដើម្បីតាមដានសកម្មភាពស៊ីចំណីរបស់ត្រី ដែលអាចសន្និដ្ឋានបានអំពីសុខភាពត្រី។<br>- ផ្លាស់ប្តូរទឹកជាប្រចាំ ដោយធ្វើការពិនិត្យគុណភាពទឹកដែលត្រូវប្តូរចូលជាមុន។<br>- មានកំបោរស ថ្នាំ Formalin និងថ្នាំពិណស្វាយ នៅក្នុងកសិកដ្ឋានចិញ្ចឹម ដើម្បីអាចគ្រប់គ្រង និងព្យាបាលជម្ងឺបានទាន់ពេល។ |
| | | តម្លៃត្រីនុយឡើងថ្លៃខ្ពស់ខុសប្រក្រតី នាំឱ្យថ្លៃដើមផលិតខ្ពស់។ | - ស្វែងរកទីតាំងប្រភពចំណីត្រីនុយលើសពី២កន្លែង<br>- សិក្សាអំពីវិធីសាស្ត្រឬបច្ចេកទេសក្នុងការផលិតចំណីកែច្នៃរមផ្សំចេញពីវត្ថុធាតុដើមក្នុងតំបន់ និងងាយរកបាន។<br>- ធ្វើកិច្ចសន្យាជាមួយអ្នកលក់ត្រីនុយ ដោយមានកាលវិភាគច្បាស់លាស់ |
| ២ | **ហានិភ័យទីផ្សារ** | តម្លៃទីផ្សារត្រីសាច់ប្រែប្រួលមិនច្បាស់លាស់។ | - សិក្សា និងស្វែងរកទីផ្សារឬឈ្មួញប្រមូលទិញឱ្យបានច្រើនកន្លែង<br>- ចងក្រងជាបណ្តុំអ្នកចិញ្ចឹមត្រី ដើម្បីភ្ជាប់ខ្សែច្រវាក់តម្លៃទីផ្សារ |
| ៣ | **ហានិភ័យហិរញ្ញវត្ថុ** | កង្វះថវិកានៅក្នុងដំណើរការចិញ្ចឹម។ កសិករមួយកាត់បន្ថយបរិមាណចំណី ឬបង្ខំចិត្តលក់ត្រីចេញទាំងត្រីនៅតូចមិនទាន់សមស្របទីផ្សារ។ | - មានផែនការអាជីវកម្មច្បាស់លាស់<br>- មានទុនបម្រុង ក្រៅពីទុនវិនិយោគ |

## ៥-សេចក្តីសន្និដ្ឋានៈ

តាមរយៈការចុះជួបកសិករផ្ទាល់បានបង្ហាញថា÷ ទោះបីជាតម្លៃទីផ្សារត្រីសាច់មិនទៀងទាត់ ប៉ុន្តែអាចទទួលបានផលចំណេញឬអាចរួចថ្លៃដើមផលិត (ក្នុងតម្លៃត្រឹម ៩០០០រៀល/គ.ក) លើកលែងតែគុណភាពត្រីសាច់ទាបខ្លាំង (ទំហំឬខ្នាតត្រីមិនស្មើគ្នា ត្រីស្គមមិនសមស្របនឹងទីផ្សារ) នោះតម្លៃអាចធ្លាក់ទាបជាងនេះបន្តិចបន្តួច។ បញ្ហាចម្បងៗមួយចំនួនបានរកឃើញមានដូចខាងក្រោម÷

- ការចិញ្ចឹមភាគច្រើនគឺតាមការសិក្សាពីគ្នាទៅវិញទៅមក ដោយពុំមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ឡើយ។
- ពីដំណាក់កាលមួយទៅមួយនៅមានចំណុចខ្វះខាតមួយចំនួនដូចជា ដំណាក់កាលនៃការជ្រើសរើសពូជត្រីមកចិញ្ចឹមនៅមិនទាន់ត្រឹមត្រូវ (ទំហំតូចពេក) បណ្តាលឱ្យអត្រាបាត់បង់ខ្ពស់។
- ការដាក់ចំណី និងការប្រើប្រាស់ចំណី តាមរយៈការប៉ាន់ស្មាន ដោយមិនមានការគណនាត្រឹមត្រូវ ពេលផ្តល់ចំណីលើស បង្កឱ្យមានការចំណាយខ្ពស់ ខាតបង់ថវិកា និងពេលខ្វះចំណី ត្រីលូតលាស់មិនស្មើគ្នា និងចំណាយពេលយូរ មិនតាមពេលកំណត់។
- មិនមានឧបករណ៍ឬសម្ភារៈសម្រាប់ពិនិត្យ និងតាមដានជាប្រចាំលើគុណភាពទឹក និងសុខភាពត្រី ដើម្បីបង្ការបញ្ហាកើតឡើងជាយថាហេតុ ដែលអាចបង្កឱ្យមានអត្រាបាត់បង់ខ្ពស់។
- ទីផ្សារនៅតែជាបញ្ហាចម្បងសម្រាប់កសិករចិញ្ចឹម ទោះបីជាមានឈ្មួញប្រមូលទិញដល់ទីកន្លែង ប៉ុន្តែតម្លៃលក់ចេញទាប និងមានការប្រែប្រួលលឿន និងមិនច្បាស់លាស់។

សរុបមក ការខ្វះខាតបច្ចេកទេស បានបង្កឱ្យតម្លៃថ្លៃដើមនៃការផលិតខ្ពស់ និងពិបាកក្នុងការប្រកួតប្រជែងទីផ្សារជាមួយផលិតផលនាំចូលពីប្រទេសជិតខាង។ ដូចនេះ ការសិក្សារៀនសូត្រ និងស្រាវជ្រាវអំពីបច្ចេកទេសថ្មីៗ គឺជាកត្តាចម្បងបំផុតសម្រាប់កសិករចិញ្ចឹមត្រីឆ្ពោរ ដើម្បីបង្កើនសមត្ថភាពផលិតកម្មទាំងបរិមាណ និងគុណភាព។ លើសពីនេះ ការសិក្សាស្វែងយល់អំពីតម្រូវការទីផ្សារត្រូវអនុវត្តជាប្រចាំ ពីព្រោះចរន្តទីផ្សារតែងមានការផ្លាស់ប្តូរទៅតាមបរិបទទីផ្សារប្រកួតប្រជែង។ លទ្ធភាពទទួលបានទុនដែលមានអត្រាការប្រាក់ទាបរបស់កសិករ គឺជាកត្តាចម្បងក្នុងការកាត់បន្ថយថ្លៃដើមផលិតកម្ម ដើម្បីដំណើរការផលិតកម្មប្រកបដោយជោគជ័យ និងមាននិរន្តរភាព៕